ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៦

# ដំណឹងជ្រើសរើសអ្នកស្ម័គ្រចិត្ត

អង្គការអង្គការស្អាតកម្ពុជា ជាអង្គការគ្រិស្តបរិស័ទក្នុងស្រុកមួយ ដែលបាននិងកំពុងអនុវត្តគម្រោងក្រោមគោលបំណងទឹកស្អាត និងអនាម័យ (WAS H)។ បេសកកម្មគឺ ដើម្បីលើកកំពស់គុណភាពទឹក អនាម័យ សុខភាព និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ក្នុងបណ្តាសហគមន៍គោលដៅដោយប្រើបច្ចេកវិទ្យា និងការអប់រំសមស្រប។ ការងារទាំងអស់ត្រូវបានធ្វើឡើងដោយសហការជាមួយថ្នាក់ដឹកនាំសហគមន៍ និងអាជ្ញាធរមូលដ្ឋាន។ អង្គការស្អាតកម្ពុជាបច្ចុប្បន្នកំពុងអនុវត្តគម្រោងរបស់ខ្លួននៅក្នុងខេត្តចំនួន ១១ ដូចជា ស្វាយរៀង ព្រៃវែង កំពង់ធំ បាត់ដំបង ពោធិ៍សាត់ ឧត្តរមានជ័យ សៀមរាប ត្បូងឃ្មុំ កំពត រតនគីរីនិង ស្ទឹងត្រែង។

អង្គការស្អាតកម្ពុជាត្រូវការជ្រើសរើសអ្នកស្ម័គ្រចិត្តរយៈពេលវែងចំនួន ០១នាក់ សម្រាប់មុខតំណែងជា **បុគ្គលិកស្ម័គ្រចិត្តផ្នែកត្រួតពិនិត្យចម្រោះទឹក (Monitoring Volunteer)** ដែលមានទីតាំងការិយាល័យនៅ **ស្រុកស្ទោង ខេត្តកំពង់ធំ**

## ១. ភារកិច្ចទទួលខុសត្រូវការងារ ៖

- ជួយសម្របសម្រួលការងារ របស់អ្នកសម្របសម្រួលត្រួតពិនិត្យចម្រោះទឹក ធ្វើកំណត់ត្រាចំនួនចម្រោះទឹកក្នុងប្រព័ន្ធ Inform Builder អោយបានត្រឹមត្រូវ តាមតម្រូវការរបស់គម្រោង រួចរាយការណ៍មកអ្នកសម្របសម្រួលត្រួតពិនិត្យចម្រោះទឹក។
- ជួយសម្របសម្រួលការងាររបស់ អ្នកសម្របសម្រួលត្រួតពិនិត្យចម្រោះទឹក ក្នុងការជំរុញ និងលើកទឹកចិត្តដល់ប្រជាពលរដ្ឋនៅក្នុងសហគមន៍អោយប្រើប្រាស់ចម្រោះទឹក។
- ជួយសម្របសម្រួលការងារ របស់អ្នកសម្របសម្រួលត្រួតពិនិត្យចម្រោះទឹកបង្រៀនដល់ប្រជាពលរដ្ឋនូវ របៀបលាងខ្សាច់ និងត្រួតពិនិត្យការលាងខ្សាច់ របស់ប្រជាពលរដ្ឋ (ដំឡើងជាថ្មី)។
- ជួយសម្របសម្រួលការងារ របស់អ្នកសម្របសម្រួលត្រួតពិនិត្យចម្រោះទឹក ដំឡើងចម្រោះទឹក ជូនប្រជាពលរដ្ឋដែលប្រកបទៅដោយគុណភាព។
- ជួយសម្របសម្រួលការងាររបស់អ្នកសម្របសម្រួលត្រួតពិនិត្យចម្រោះទឹក បង្រៀនឡើងវិញដល់ប្រជាពលរដ្ឋអំពីរបៀបថែទាំចម្រោះទឹក ការប្រើប្រាស់ នៅពេលដែលដំឡើងចម្រោះទឹកនៅតាមផ្ទះនីមួយៗ ។

## ២. លក្ខខណ្ឌនៃការជ្រើសរើស ៖

- បញ្ចប់ថ្នាក់វិទ្យាល័យ។
- មានសមត្ថភាពពន្យល់ដល់សហគមន៍ អំពីការថែទាំ និង ការប្រើប្រាស់ចម្រោះទឹកដល់ប្រជាជននៅក្នុងសហគមន៍។
- អាចសរសេរ របាយការណ៍ និង ដឹងច្បាស់អំពីភូមិសាស្ត្រ។
- ប្តេជ្ញាតាមបេសកកម្ម និង គុណតម្លៃរបស់អង្គការស្អាតកម្ពុជា។
- មានឆន្ទៈក្នុងការធ្វើការជាមួយសហគមន៍និងធ្វើការងារជាក្រុម។
- មានម៉ូតូប្រើប្រាស់ផ្ទាល់ខ្លួន។

ចំពោះបេក្ខជនទាំងពីរភេទដែលមានចំណាប់អារម្មណ៍ជាមួយមុខតំណែងនេះ សូមមកទទួលយកពាក្យសុំធ្វើការងារនៅការិយាល័យ **ខេត្តកំពង់ធំ** ឬ អាចទាញយកពាក្យសុំបម្រើការងារជាភាសា ខ្មែរ ឬ អង់គ្លេស ទៅបំពេញហើយបញ្ជូនមកវិញដោយភ្ជាប់ជាមួយប្រវត្តិរូប សង្ខេប (**CV & Cover Letter)** រួចបញ្ជូនមកកាន់ការិយាល័យ **កំពង់ធំ** តាមរយៈអាសយដ្ឋានខាងលើ ឬទំនាក់ទំនងទូរស័ព្ទលេខ: (៨៨៥)-២៣៨៨០១៦៤, E-mail: hr@clearcambodia.org, Website: www.clearcambodia.org.

***សំគាល់:*** សូមភ្ជាប់មកជាមួយនូវឯកសារថតចំលងអត្តសញ្ញាណប័ណ្ណ សំបុត្រកំណើត ប័ណ្ណគ្រួសារ ឬសៀវភៅស្នាក់នៅ និង ឯកសារពាក់ព័ន្ធ ផ្សេងទៀត និងរូបថត ៤x៦ ចំនួន ២សន្លឹក។

បន្ទាប់ពីពិនិត្យលើសំណុំបែបបទសុំបំរើការងារអ្នកជាប់បញ្ជីសម្រាំង និងត្រូវបានធ្វើការទំនាក់ទំនង ដើម្បីធ្វើការសម្ភាសន៍។

**ថ្ងៃផុតកំណត់ទទួលពាក្យនៅ ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៦**